# ខោនធី LOS ANGELES
# មន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា/ស្មៀនខោនធី

## សំណួរដែលគេសួរជាញឹកញាប់អំពីការបោះឆ្នោតសាកល នៅខែវិច្ឆិកា ឆ្នាំ 2022

### ការចុះឈ្មោះអ្នកបោះឆ្នោត

**តើខ្ញុំអាចចុះឈ្មោះបោះឆ្នោតរបៀបណា?**

- វិធីដែលងាយស្រួលបំផុតដើម្បីចុះឈ្មោះបោះឆ្នោតគឺតាមអ៊ិនធើណែតនៅ LAVOTE.GOV។
- ពាក្យសុំចុះឈ្មោះបោះឆ្នោតអាចរកបាននៅអាគាររដ្ឋាភិបាលភាគច្រើនដូចជាបណ្ណាល័យ ការិយាល័យយានយន្តនិង នៅការិយាល័យចុះបញ្ជីនៅ Norwalk ។
- អ្នកបោះឆ្នោតត្រូវចុះឈ្មោះឲ្យទាន់ថ្ងៃទី **24 តុលា** ដើម្បីទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រសំរាប់ការបោះឆ្នាតលើកនេះ។

**តើខ្ញុំឆែកពីស្ថានភាពចុះឈ្មោះរបស់ខ្ញុំតាមរបៀបណា?**

- អ្នកបោះឆ្នោតអាចពិនិត្យស្ថានភាពចុះឈ្មោះនិងព័ត៌មានរបស់ពួកគេតាមអ៊ិនធើណែតនៅ LAVOTE.GOV/VRSTATUS ឬទូរស័ព្ទទៅ (800) 815-2666 ជម្រើស 2 ។

**តើខ្ញុំនៅតែអាចបោះឆ្នោតបានឬទេ ប្រសិនបើខ្ញុំខកខានមិនបានចុះឈ្មោះឲ្យទាន់ថ្ងៃផុតកំណត់?**

- បាន។ អ្នកបោះឆ្នោតដែលមានសិទ្ធិ ដែលខកខានមិនបានចុះឈ្មោះឲ្យទាន់ថ្ងៃផុតកំណត់គឺនៅ ថ្ងៃទី **24 តុលា** នៅតែអាចបោះឆ្នោតដោយផ្ទាល់ខ្លួននៅមណ្ឌលបោះឆ្នោតក្នុងខោនធី L.A. តាមរយៈអ្នកបោះឆ្នោតតាមលក្ខខណ្ឌ (ចុះឈ្មោះក្នុងថ្ងៃតែមួយ)។

**តើខ្ញុំគួរធ្វើបច្ចុប្បន្នភាពព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតរបស់ខ្ញុំនៅពេលណានិងរបៀបណា?**

- បើសិនអ្នកបោះឆ្នោតប្តូរលំនៅដ្ឋាន ប្តូរឈ្មោះ ឬចង់ប្តូរគណៈបក្សនយោបាយ ពួកគេអាចធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះនៅ LAVOTE.GOV។ ចំណែកអ្នកបោះឆ្នោតដែលប្តូរចេញពីខោនធីឬរដ្ឋ សូមទាក់ទងមក ការិយាល័យចុះបញ្ជីតាមលេខ (800) 201-8999 ជម្រើស 2 ដើម្បីលុបចោលការចុះឈ្មោះរបស់អ្នក ឬចូលទៅ LAVOTE.GOV ដើម្បីទាញយកបែបបទលុបការចុះឈ្មោះ ។

---

### បោះឆ្នោតតាមសំបុត្រ

**តើពេលណាដែលខ្ញុំនឹងទទួលបាននូវសន្លឹកឆ្នោតបោះតាមសំបុត្ររបស់ខ្ញុំ?**

- សន្លឹកឆ្នោតបោះតាមសំបុត្រត្រូវបានផ្ញើជូនអ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ ចាប់ផ្តើមពីថ្ងៃទី **6 ខែតុលា** ។

**តើខ្ញុំតាមដានសន្លឹកឆ្នោតបោះតាមសំបុត្ររបស់ខ្ញុំរបៀបណា?**

- អ្នកបោះឆ្នោតអាចតាមដានសន្លឹកឆ្នោតរបស់គេដោយជាវជាមួយនឹង **Where's My Ballot** នៅ california.ballottrax.net ។នេះជាការជាវមួយដែលមិនគិតថ្លៃ ដែលផ្ញើសេចក្តីជូនដំណឹងជាស្វ័យប្រវត្តិតាម សារជាអក្សរ អ៊ីម៉ែល ឬសារសម្លេង ពីស្ថានភាពឆ្នោតអ្នក។

**តើខ្ញុំរកបញ្ជីនៃទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតនៅឯណា?**

- តាមអ៊ិនធើណែតនៅ LAVOTE.GOV.។
- បញ្ជីទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតដែលងាយស្រួលនៅជិតលំនៅដ្ឋានអ្នកបោះឆ្នោត គឺបញ្ចូលនៅក្នុងកញ្ចប់បោះឆ្នោតតាមសំបុត្រ។

**ហេតុអ្វីបានជាខ្ញុំត្រូវចុះហត្ថលេខាលើស្រោមសំបុត្របញ្ជូនមកវិញ?**

- មន្ត្រីចុះបញ្ជីផ្ទៀងផ្ទាត់ហត្ថលេខានៅលើស្រោមសំបុត្រផ្ញើត្រឡប់មកវិញ ជាមួយនឹងហត្ថលេខានៅក្នុងឯកសារចុះឈ្មោះអ្នកបោះឆ្នោតដើម្បីបញ្ជាក់សិទ្ធិ។

**តើខ្ញុំដាក់ថ្ងៃខែកំណើតរបស់ខ្ញុំនៅលើស្រោមសំបុត្រប្រគល់មកវិញ ឬក៏កាលបរិច្ឆេទបញ្ជូនត្រឡប់មកវិញ?**

- បញ្ចូលថ្ងៃខែដែលសន្លឹកឆ្នោតផ្ញើមកវិញ ។ ប្រសិនបើអ្នកបោះឆ្នោតបញ្ចូលថ្ងៃខែកំណើតរបស់ពួកគាត់ជំនួសវិញនោះ ឆ្នោតនឹងនៅតែដំណើរការ ហើយនៅពេលដែលបានផ្ទៀងផ្ទាត់រួចហើយ សន្លឹកឆ្នោតនឹងត្រូវបានរាប់ ។

**តើខ្ញុំត្រូវបញ្ជូនសន្លឹកឆ្នោតរបស់ខ្ញុំទៅវិញនៅពេលណា?**

- អ្នកបោះឆ្នោតអាចបញ្ជូនសន្លឹកឆ្នោតរបស់ពួកគេមកវិញនៅពេលដែលគេទទួលបានសន្លឹកឆ្នោត។
- ឆ្នោតទាំងអស់ត្រូវតែបានបោះត្រាប្រៃសនីយ៍ឬបញ្ជូនទៅប្រអប់ទម្លាក់សន្លឹកឆ្នោតផ្លូវការ ឬមណ្ឌលបោះឆ្នោតឲ្យទាន់ថ្ងៃបោះឆ្នោត។
- មន្ត្រីចុះបញ្ជីនឹងទទួលឆ្នោតដែលមានបោះត្រាប្រៃសនីយ៍នៅថ្ងៃបោះឆ្នោត ហើយទទួលបានក្នុងអម្លុង 7 ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

# ខោនធី LOS ANGELES
# មន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា/ស្មៀនខោនធី

## សំណួរដែលគេសួរជាញឹកញាប់អំពីការបោះឆ្នោតសាកល នៅខែវិច្ឆិកា ឆ្នាំ 2022

## បោះឆ្នោតតាមសំបុត្រ

### ចុះបើខ្ញុំមិនបានទទួលសន្លឹកឆ្នោត ឬសន្លឹកឆ្នោតត្រូវបានខូចខាត?

- អ្នកបោះឆ្នោតអាចធ្វើការស្នើសុំសន្លឹកឆ្នោតជំនួសមួយនៅ LAVOTE.GOV/REPLACEBALLOT។ ថ្ងៃចុងក្រោយដែលត្រូវស្នើសុំសន្លឹកឆ្នោតជំនួសគឺ ថ្ងៃទី **1 ខែវិច្ឆិកា** ។
- ទូរស័ព្ទ (800) 815-2666, ជម្រើស 2, ឬ អ៊ីម៉ែល votebymail@rrcc.lacounty.gov ជាមួយឈ្មោះពេញរបស់អ្នក ថ្ងៃខែឆ្នាំកំណើត, និងអាសយដ្ឋាន ។

### តើខ្ញុំស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្រជាភាសាផ្សេងតាមរបៀបណា?

- បំពេញ និងបញ្ជូនទម្រង់ពាក្យសុំភាសានៅខាងក្រោយសៀវភៅសន្លឹកឆ្នោតគំរូ។
- ទូរស័ព្ទទៅផ្នែកសេវាពហុភាសាមន្ត្រីចុះបញ្ជីតាមលេខ (800) 815-2666 ជម្រើសទី 3 ។
- ភាសាដែលគាំទ្រ៖ អាមេនី ចិន ខ្មែរ ហ្វាស៊ី កូរ៉េ អេស្ប៉ាញ តាកាឡុក វៀតណាម ហិណ្ឌូ ជប៉ុន ថៃ រុស្ស៊ី ភូមា តេលូហ្គូ ហ្គូចារ៉ាទី ឥណ្ឌូនេស៊ី ម៉ុងហ្គោលី និងបេងហ្គាល់។

---

## បោះឆ្នោតដោយផ្ទាល់ខ្លួន

### តើខ្ញុំអាចបោះឆ្នោតដោយផ្ទាល់ខ្លួនបានដែរឬទេ?

- បាន។ អ្នកបោះឆ្នោតនឹងមានជម្រើសក្នុងការបោះឆ្នោតផ្ទាល់នៅមណ្ឌលបោះឆ្នោតណាមួយចាប់ពីថ្ងៃទី **29 ខែតុលា ។**
- មណ្ឌលបោះឆ្នោតនឹងបើកជារៀងរាល់ថ្ងៃពីម៉ោង 10 ព្រឹកដល់ 7 យប់ ហើយថ្ងៃបោះឆ្នោតពីម៉ោង 7 ព្រឹកដល់ម៉ោង 8 យប់។

### តើខ្ញុំរកទីតាំងមណ្ឌលបោះតាមបានតាមរបៀបណា?

- ចូលទៅ LOCATOR.LAVOTE.GOV ដើម្បីមើលកម្មវិធី Vote Center ឬទូរស័ព្ទទៅ (800) 815-2666 ជម្រើស 1 ។
- កម្មវិធីនឹងបង្ហាញនូវទីតាំងមណ្ឌលបោះឆ្នោតទាំងអស់ក្នុងខោនធី LA និងការប៉ាន់ស្មាននូវពេលវេលារង់ចាំ។
- រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះនឹងត្រូវបានផ្ញើជូននូវសំបុត្រដាច់ដោយឡែកមួយទៀតនៅពាក់កណ្ដាលខែឧសភា ដែលរាយបញ្ជីទីតាំងមណ្ឌលបោះឆ្នោតដែលនៅជិតផ្ទះរបស់ពួកគេ។

### តើពេលណាដែលខ្ញុំអាចទៅបោះឆ្នោតផ្ទាល់ខ្លួនបាន?

- អ្នកបោះឆ្នោតអាចទៅមណ្ឌលបោះឆ្នោតណាមួយក៏បាន ចាប់ផ្ដើមពីថ្ងៃទី **29 ខែតុលា ។**
- ទាញយកប្រយោជន៍ពីឱកាសបោះឆ្នោតមុនកាលកំណត់ និងបោះឆ្នោតឱ្យបានឆាប់។

### តើអ្នកធ្វើដូចម្ដេចដើម្បីរក្សាមណ្ឌលបោះឆ្នោតឱ្យមានសុវត្ថិភាពពី កូវីដ-19?

- មណ្ឌលបោះឆ្នោតទាំងអស់អនុវត្តតាមគោលការណ៍ណែនាំសុខភាពនិងសុវត្ថិភាពសាធារណៈបច្ចុប្បន្ន។
- បុគ្គលិកបំរើការបោះឆ្នោតនឹងពាក់ម៉ាស់មុខហើយជូតសំអាតផ្ទៃនានាជាប្រចាំ។
- អ្នកបោះឆ្នោតត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំងឱ្យពាក់ម៉ាស់មុខ។

### តើខ្ញុំត្រូវផ្ដល់អត្តសញ្ញាណប័ណ្ណរបស់ខ្ញុំដើម្បីបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែរឬទេ?

- ច្បាប់រដ្ឋកាលីហ្វ័រញ៉ាមិនតម្រូវឱ្យអ្នកចុះឈ្មោះបោះឆ្នោតបង្ហាញអត្តសញ្ញាណនៅពេលបោះឆ្នោតនោះទេ។
- ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកបោះឆ្នោតចុះឈ្មោះជាលើកដំបូង ពួកគេត្រូវតែផ្ដល់អត្តសញ្ញាណប័ណ្ណដែលមានរូបថតរដ្ឋាភិបាលត្រឹមត្រូវ ឬលេខបួនខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គម។